AI Index: ASA 23/8825/2018

AMNESTY INTERNATIONAL

AMNESTY INTERNATIONAL INTERNATIONAL SECRETARIAT
Peter Benenson House, 1 Easton Street
London WC1X 0DW, United Kingdom
T: +44 (0)20 7413 5500 F: +44 (0)20 7956 1157
E: amnestyis@amnesty.org W: www.amnesty.org

២៥ ខែកក្កដា ២០១៨

ប្រទេសកម្ពុជា ៖ ការរំលោភបំពានសិទ្ធិមនុស្សដែលត្រូវមានការដោះស្រាយនៅមុនការបោះឆ្នោតជាតិ

ចំពោះរដ្ឋាភិបាលកម្ពុជា និងគណបក្សនយោបាយនានាដែលចូលរួមក្នុងការបោះឆ្នោតជាតិនៅថ្ងៃទី២៩ ខែកក្កដា ៖ អង្គការលើកលែងទោសអន្តរជាតិ សូមអំពាវនាវឲ្យរដ្ឋាភិបាលកម្ពុជា និងគ្រប់គណបក្សនយោបាយទាំងអស់ ដែលចូលរួមក្នុងការបោះឆ្នោតជាតិ ដែលគ្រោងធ្វើនៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៨ ប្តេជ្ញាចំពោះការធានាឲ្យបានថា កាតព្វកិច្ចសិទ្ធិមនុស្សជាអន្តរជាតិរបស់កម្ពុជា ត្រូវបានផ្តល់ជាអាទិភាព ក្នុងអំឡុងពេលនៃយុទ្ធនាការ និងក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោត និងសូមឲ្យអាជ្ញាធរគោរព ការពារ បំពេញនិងលើកស្ទួយសិទ្ធិទាំងនេះ។

ការបង្ក្រាបកាន់តែខ្លាំងឡើង នៅក្នុងរយៈពេលពីរឆ្នាំ ឆ្ពោះទៅរកការបោះឆ្នោតជាតិ

ការបង្ក្រាបលើការប្រឆាំងជំទាស់ដោយសន្តិវិធីនៅកម្ពុជា បន្តធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋកម្ពុជា។ សេចក្តីថ្លែងការណ៍ផ្ទាល់មាត់របស់អង្គការលើកលែងទោសអន្តរជាតិស្តីពីកម្ពុជា ទៅកាន់សម័យប្រជុំលើកទី៣៧ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានរំលឹកឡើងវិញ[1]នូវការបន្តថយចុះយ៉ាងឆាប់រហ័សនូវលំហសម្រាប់សកម្មជនសន្តិភាព សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងគណបក្សប្រឆាំងដែលត្រូវប្រើប្រាស់សិទ្ធិមនុស្សរបស់ពួកគេក្នុងការបញ្ចេញមតិដោយសេរី ការជួបជុំគ្នាដោយសន្តិវិធី និងខាងសមាគម។ យើងក៏បានសម្តែងការព្រួយបារម្ភផងដែរអំពីឯករាជ្យភាពរបស់តុលាការ និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក៏ដូចជាភាពញឹកញាប់នៃការចាប់ខ្លួនតាមអំពើចិត្ត និងស្ថានភាពមិនល្អនៃសិទ្ធិរបស់ស្ត្រី។

បន្ទាប់ពីការបោះឆ្នោតឃុំសង្កាត់ខែមិថុនាឆ្នាំ២០១៧ អាជ្ញាធរបានចាប់ផ្តើមបិទប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដែលបង្កើតឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សេរីភាពសារព័ត៌មាន ដែលបានបង្ខំឱ្យអ្នកសារព័ត៌មានជាច្រើន ធ្វើការហាមឃាត់ខ្លួនឯង។ នៅខែកញ្ញា រដ្ឋាភិបាលបានបិទស្ថានីយវិទ្យុចំនួន ៣២ ដែលបានចាក់ផ្សាយកម្មវិធីវិទ្យុអាស៊ីសេរី សម្លេងសហរដ្ឋអាមេរិក និងសម្លេងប្រជាធិបតេយ្យ។[2] អ្នកសារព័ត៌មានវិទ្យុអាស៊ីសេរី អ៊ុនឈិន និងយៀងសុធារិន ត្រូវបានចាប់ខ្លួនពីបទចោទថា៖ “ចារកម្ម” ចំពោះការបន្តការរាយការណ៍។[3]

ការប្រើច្បាប់បង្ក្រាបសេរីភាពខាងការបញ្ចេញមតិ ការប្រជុំ និងសមាគម

រដ្ឋាភិបាលក៏បានគំរាមកំហែងផងដែរចំពោះសកម្មភាពស្របច្បាប់ប្រឆាំងនឹងអ្នកដែល "អំពាវនាវ ញុះញង់ ឬ រារាំងប្រជាពលរដ្ឋទៅបោះឆ្នោត" បន្ទាប់ពីក្រុមប្រឆាំងដែលត្រូវបានគេហាមឃាត់ អំពាវនាវឱ្យធ្វើពហិការ

[1] អង្គការលើកលែងទោសអន្តរជាតិ, សេចក្តីថ្លែងផ្ទាល់មាត់របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិស្តីពីកម្ពុជានិងលីប៊ី (កម្មវិធីជជែកដេញដោលទូទៅលើកទី ១០, សម័យប្រជុំលើកទី៣៧) (លិបិក្រម IOR 40/8119/2018)

[2] អាញ្ញាញ់ បាលីហ្គា, មាជងារា និងញៀមឆេង "វិទ្យុអាស៊ីសេរី បិទប្រតិបត្តិការនៅប្រទេសកម្ពុជានៅចំពេលមានការបង្ក្រាបប្រព័ន្ធផ្សព្វផ្សាយ" កាសែតភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១៧។

[3] អង្គការលើកលែងទោសអន្តរជាតិ, កម្ពុជា ៖ អតីតអ្នកសារព័ត៌មាន ត្រូវបានចោទប្រកាន់ពីបទចារកម្ម)លេខទំព័រ :ASA 23/7563/2017)

ចំពោះចូលរួមបោះឆ្នោតដែលគណបក្សកំពុងកាន់អំណាចអះអាងថាជា៖ "ការញុះញង់ដើម្បីរារាំងការបោះឆ្នោត។"[4]

លើសពីនេះ ទោះបីសេរីភាពនៃការជួបជុំគ្នាដោយសន្តិវិធី ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញក៏ដោយ ក៏សកម្មជន និងអ្នកការពារសិទ្ធិមនុស្សដែលចូលរួមក្នុងបាតុកម្មអហិង្សា នៅតែប្រឈមនឹងអន្តរាគមន៍ ការចាប់ខ្លួន និងអំពើហិង្សាពីប៉ូលីស និងអាជ្ញាធរក្រៅច្បាប់ផ្សេងទៀតដែរ។ ច្បាប់ឆ្នាំ២០០៩ស្តីពីបាតុកម្មដោយសន្តិភាព (LPD) មានបញ្ហាបទប្បញ្ញត្តិមិនច្បាស់លាស់ស្តីពីនីតិវិធី ដែលអ្នករៀបចំតវ៉ាត្រូវប្រើប្រាស់ ដើម្បីឲ្យការតវ៉ាមួយអាចស្របច្បាប់ ដែលនេះជាការកេងប្រវ័ញ្ច តាមរយៈការតម្រូវឱ្យមាន "ការយល់ព្រម" ជាផ្លូវការសម្រាប់ព្រឹត្តិការណ៍សាធារណៈ។ ទោះបីភាគច្រើនលើសលប់នៃការប្រមូលផ្តុំគ្នាជាសាធារណៈ ធ្វើឡើងដោយសន្តិវិធី និងទោះជាមិនមានយុត្តិកម្មសម្រាប់ការប្រើកងកម្លាំងក៏ដោយ ក៏កម្លាំងសន្តិសុខជារឿយៗ ប្រើកម្លាំងមិនចាំបាច់ និងហួសប្រមាណ ដើម្បីបំបែកទាំងការប្រជុំសន្តិវិធី និងអ្នកទាំងឡាយដែលមានធាតុហិង្សាដែរ។[5]

លើសពីនេះទៅទៀត រដ្ឋាភិបាលកម្ពុជា បន្តការគាបសង្កត់សង្គមស៊ីវិលដែលកំពុងរួញថយចុះនៅក្នុងប្រទេសនេះ តាមរយៈការប្រើប្រាស់ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ដែលអនុញ្ញាតឲ្យរដ្ឋាភិបាលនេះ ព្យួរសកម្មភាពរបស់អង្គការនានា គំរាមកំហែង ឬបិទពួកគេទាំងស្រុង។[6] ច្បាប់ ត្រូវបានគេយកមកប្រើរួចទៅហើយ ដើម្បីគំរាមបិទមជ្ឈមណ្ឌលសមភាពកម្ពុជា និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ដោយផ្អែកលើមូលដ្ឋានមិនពិត ដូចជាការទទួលមូលនិធិបរទេសជាដើម។

មិនយូរប៉ុន្មានមុនការបោះឆ្នោតឃុំ/សង្កាត់ខែមិថុនាឆ្នាំ២០១៧ រដ្ឋសភាក៏បានអនុម័តវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលផ្តល់អំណាចឥតកំណត់ដល់អង្គការនីតិប្រតិបត្តិ ក្នុងការលុបបំបាត់គណបក្សនានា មិនឱ្យចូលរួមក្នុងការបោះឆ្នោត ហាមឃាត់សមាជិករបស់ពួកគេពីសកម្មភាពនយោបាយអស់រយៈពេល ៥ ឆ្នាំ ហើយថែមទាំងរំលាយគណបក្ស ប្រសិនបើពួកគេត្រូវបានចោទប្រកាន់ថាបានជាប់ពាក់ព័ន្ធក្នុងអំពើខុសឆ្គងមិនច្បាស់លាស់ ដូចជាការគំរាមកំហែងដល់ភាពស្និតរួមតរបស់សង្គមកម្ពុជា។[7] បន្ទាប់ពីការបោះឆ្នោត ហើយមិនយូរប៉ុន្មានក្រោយពីលោក កឹម សុខា មេដឹកនាំគណបក្សប្រឆាំង ត្រូវបានគេចាប់ដាក់ពន្ធនាគារ ច្បាប់នេះត្រូវបានតុលាការយកទៅអនុវត្តរំលាយគណបក្សនយោបាយដ៏សំខាន់មួយ នោះគឺគណបក្សសង្គ្រោះជាតិ (CNRP) ដោយហេតុផលថា ពួកគេបានគ្រោងធ្វើ "បដិវត្តន៍ពណ៌"[8] និងសមាជិកគណបក្សជាន់ខ្ពស់ចំនួន ១១៨ រូប ត្រូវបានហាមឃាត់ពីសកម្មភាពនយោបាយរយៈពេលប្រាំឆ្នាំ។[9]

នៅខែមេសាឆ្នាំ២០១៦ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីសហជីព ដែលដាក់កំហិតយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិសេរីភាពខាងសមាគម និងរំលោភបំពានលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ ដែលបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជា ដោយផ្តល់អំណាចយ៉ាងទូលំទូលាយ ដើម្បីបញ្ឈប់សកម្មភាពប្រមូលផ្តុំ បិទសហជីពនិងហាមឃាត់កូដកម្មតាមឆន្ទៈ។[10] រឿងនេះកើតឡើងបន្ទាប់ពីអាជ្ញាធរបានបាញ់សម្លាប់យ៉ាងហោចណាស់កម្មករសំណង់ក្រុមកាត់ដេរដែលកំពុងធ្វើកូដកម្មចំនួន ៥ នាក់ និងបានបាញ់សម្លាប់យ៉ាងហោចណាស់ ៤០ នាក់ផ្សេងទៀត ក្នុងអំឡុងបាតុកម្មនៅទូទាំងប្រទេសរបស់កម្មករកាត់ដេរនៅក្រោយការបោះឆ្នោតចុងក្រោយ។[11]

តុលាការអយុត្តិធម៌

អ្នកការពារសិទ្ធិមនុស្ស តែងតែជួបប្រទះការធ្វើទុក្ខបុកម្នេញជាទៀងទាត់ ចំពោះការងាររបស់ពួកគេក្នុងការការពារ និងលើកស្ទួយសិទ្ធិមនុស្ស ខណៈដែលសកម្មជននិងអ្នកប្រឆាំងដទៃទៀត ត្រូវបានប៉ូលីស ឬអាជ្ញាធរគំរាមកំហែងជាទៀងទាត់ ចំពោះសកម្មភាពនិយមសន្តិភាពរបស់ពួកគេ។ អាជ្ញាធរកម្ពុជា បានបន្តចាប់ខ្លួន

---

[4] Angaindrankumar Gnanasagaran, "ប្រទេសកម្ពុជាព្រមានប្រឆាំងនឹង "ពហិការម្រាមដៃស្ងាត" កាសែតអាស៊ានប៉ុស្តិ៍ថ្ងៃទី១៩ ខែមិថុនាឆ្នាំ២០១៨

[5] អង្គការលើកលែងទោសអន្តរជាតិ, ដើរឆ្ពោះទៅឯងផ្លូវ ៖ សេរីភាពនៃការជួបជុំដោយសន្តិវិធីនៅកម្ពុជា)លិបិក្រម៖ ASA 23/1506/2015)

[6] អង្គការលើកលែងទោសអន្តរជាតិ, កម្ពុជា ៖ ការបង្ក្រាបជាបន្តបន្ទាប់លើការប្រឆាំងនឹងនយោបាយ, សង្គមស៊ីវិលនិងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ត្រូវតែទទួលបានការដោះស្រាយដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (លិបិក្រម: ASA 23/7909/2018)

[7] ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស, ការវិភាគសិទ្ធិមនុស្សលើច្បាប់វិសោធនកម្មស្តីពីគណបក្សនយោបាយ)2017), ឆ្នាំ2017
http://cambodia.ohchr.org/en/news/ohchr-releases-human-rights-analysis-recently-amended-law-political-parties

[8] អង្គការលើកលែងទោសអន្តរជាតិ, កម្ពុជា; ការហាមប្រាមគណបក្សប្រឆាំង ជា"អំពើគាបសង្កត់នយោបាយដោយឥតលាក់លៀម) "សេចក្តីប្រកាសព័ត៌មានថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧)

[9] លោកបែនសុខហៀន "ព័ត៌មានបន្ទាន់៖ តុលាការសម្រេចរំលាយគណបក្សសង្គ្រោះជាតិ", កាសែតភ្នំពេញប៉ុស្តិ៍, ថ្ងៃទី16 ខែវិច្ឆិកាឆ្នាំ2017

[10] ដូចជា សេរីភាពនៃសមាគមនិងការពារសិទ្ធិក្នុងការរៀបចំការជួបប្រជុំ 1948 (លេខ 87) ។ និងសិទ្ធិក្នុងការរៀបចំនិងអនុសញ្ញាស្តីពីការតវ៉ាជាសមូហភាព 1949 (លេខ 98)

[11] លោកម៉ិចដាវ៉ានិងលោកអាឡិចវីល្លីមមីនស៍, "ការរាបរាប់ឡើងវិញពីការវាយប្រហារដោយទាហានប៉ូលីស", ខេមបូឌាដេលីថ្ងៃអង្គារទី 8ខែមករាឆ្នាំ 2014

និងឃាត់ឃាំងពួកសកម្មជន និងអ្នកតវ៉ាដទៃទៀត ដោយគ្មានដីកាតុលាការសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន និង "ការអប់រំកែប្រែឡើងវិញ។ "[12] មិនមានមូលដ្ឋានច្បាប់សម្រាប់ការចាប់ខ្លួនបែបនេះទេ ប៉ុន្តែអ្នកដែលជាប់ឃុំឃាំងត្រូវបានគេគាបសង្កត់ ឱ្យអនុវត្តតាមសំណើរបស់ប៉ូលីស ដោយខ្លាចការដាក់បន្ថែមទៀត ប្រសិនបើពួកគេបដិសេធមិនសហការ។ ពួកគេត្រូវបានដោះលែង បន្ទាប់ពីបានព្រមព្រៀងថា ពួកគេនឹងមិនបន្តសកម្មភាពរបស់ពួកគេ ហើយត្រូវបានគេបង្ខំឱ្យផ្តិតមេដៃលើសេចក្តីថ្លែងការណ៍ជាផ្លូវការរបស់ប៉ូលីស ក្រោមឥទ្ធិពលដដែលនោះ។[13]

ដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងសកម្មជន អ្នកគាំទ្រនយោបាយ និងអ្នកការពារសិទ្ធិមនុស្ស ត្រូវបានផ្តួចផ្តើមធ្វើដូចគ្នា នឹងការធ្វើនៅក្នុងប្រព័ន្ធតុលាការ ហើយគេបន្តច្រើនលើកដោយឥតកំណត់, ជាញឹកញាប់ អស់ពេលជាច្រើនឆ្នាំ, សម្រាប់ហេតុផលនយោបាយដ៏ហួសហេតុ។ ប្រព័ន្ធយុត្តិធម៌កម្ពុជាដែលមានលក្ខណៈនយោបាយមានបំណងតិចតួចក្នុងការបង្ហាញតែសំបកក្រៅអំពីឯករាជ្យភាព និងការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលបានធានាក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ក្រមព្រហ្មទណ្ឌ ត្រូវបានប្រើជាប្រចាំដើម្បីពង្រឹងវត្តបំណងនយោបាយប្រចាំថ្ងៃរបស់រដ្ឋាភិបាល។

តួនាទីសំខាន់ចាំបាច់របស់រដ្ឋាភិបាលនិងគណបក្សនយោបាយ

ទាំងរដ្ឋាភិបាល ទាំងគណបក្សនយោបាយដែលនៅសល់ចូលរួមប្រកួតប្រជែងយកដំណែង ក្នុងការបោះឆ្នោតជាតិនៅថ្ងៃទី២៩ ខែកក្កដា មានតួនាទីសំខាន់ក្នុងការធានាថា ការលើកស្ទួយសិទ្ធិមនុស្ស ត្រូវបានផ្តល់ជាអាទិភាព ក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត និងបន្ទាប់ពីនេះ។ ក្នុងន័យនេះ យើងសូមជំរុញឱ្យគ្រប់គណបក្សនយោបាយទាំងអស់ ប្រើនូវមធ្យោបាយទាំងអស់ ដែលអាចមាន ដើម្បីជំរុញអនុសាសន៍អនុវត្ត ដែលបានគូសបញ្ជាក់ដូចខាងក្រោម ហើយធានាថា សិទ្ធិមនុស្សនៅតែស្ថិតក្នុងជួរមុខនៃការជជែកវែកញែក ក្នុងប្រទេសកម្ពុជាទាំងក្នុងពេលបច្ចុប្បន្ននិងក្នុងពេលអនាគត។

- កែប្រែ ឬលុបចោលច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី (LPD) ដើម្បីឲ្យមូលដ្ឋានដែលគេប្រើដាក់បង្ខំលើសិទ្ធិសេរីភាពក្នុងការជួបប្រជុំគ្នា អនុលោមទៅតាមច្បាប់សិទ្ធិមនុស្ស និងបទដ្ឋានស្តីពីសេរីភាពក្នុងការជួបជុំគ្នាដោយសន្តិវិធី រួមទាំងមាត្រា២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ជំនួសឲ្យការប្រើប្រាស់ច្បាប់នេះតាមតែអំពើចិត្ត ដើម្បីហាមឃាត់ការជួបជុំណាមួយ។

- អនុម័តច្បាប់ និងចេញបទប្បញ្ញត្តិអនុវត្តពិស្តារ ដែលកំណត់នូវក្រមសីលធម៌ទូលំទូលាយស្តីពីការប្រើប្រាស់កម្លាំងដោយបុគ្គលិកអនុវត្តន៍ច្បាប់ទាំងអស់នៅកម្ពុជា ស្របតាមគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការប្រើប្រាស់កម្លាំងនិងអាវុធដោយមន្ត្រីអនុវត្តន៍ច្បាប់ និងបទដ្ឋានសិទ្ធិដទៃទៀត។

- បញ្ចប់ការគាបសង្កត់លើប្រតិបត្តិការ និងសកម្មភាពនិយមរបស់អង្គការមិនមែនរដ្ឋាភិបាល និងកែប្រែ ឬលុបចោលច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា ដោយឥរិយាបើកចំហ ជាសាធារណៈ និងមានតម្លាភាព និងដោយមានការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលនិងសាធារណជន ហើយស្រដៀងគ្នានេះ កែប្រែ ឬលុបចោលច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់សហជីព ដើម្បីឲ្យស្របតាមច្បាប់សិទ្ធិមនុស្ស និងច្បាប់ការងារ។

- គោរពសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋកម្ពុជា រួមទាំងប្រព័ន្ធផ្សព្វផ្សាយសង្គម និងបញ្ចប់គោលនយោបាយនិងការអនុវត្តការឃុំឃាំងតាមតែអំពើចិត្ត និង "អប់រំកែប្រែឡើងវិញ" លើអ្នកតវ៉ា ដែលបានចូលរួមក្នុងសកម្មភាពដោយសន្តិវិធី ដូចជាការដាក់ញត្តិទៅរដ្ឋាភិបាល ការប្រមូលផ្តុំជាសាធារណៈ ដើម្បីផ្សព្វផ្សាយពីភាពមិនសប្បាយចិត្ត ឬការបញ្ចេញទស្សនៈរបស់ពួកគេនៅទីសាធារណៈ។

[12] ពេជ្រសុធារី កាសែតភ្នំពេញប៉ុស្តិ៍ថ្ងៃទី "ឃុវជនត្រូវបានឃុំខ្លួនដោយការតវ៉ា"27 ខែកក្កដាឆ្នាំ 2018

[13] ឡេងលេន សកម្មជនប្រឆាំងការ"ប្ងមខ្សាច់ត្រូវបានទំចាប់ខ្លួនចំពោះការចតសូប និងញុះញង់ឲ្យមានអ្នកតវ៉ា", កម្ពុជាឆេលីថ្ងៃទី 8ខែសីហា 2017

- គោរពឯករាជ្យភាពរបស់ស្ថាប័នតុលាការនិងស្ថាប័នពាក់ពន្ធ័ដទៃទៀត ជាពិសេស ជានានៅក្នុងច្បាប់ គោលនយោបាយ និងអនុវត្តឯករាជ្យភាព និងភាពមិនលំអៀងរបស់តុលាការ។

- បញ្ចប់ការប្រើប្រាស់ការចោទប្រកាន់ខាងព្រហ្មទណ្ឌ និងការប្រើប្រព័ន្ធច្បាប់ជាទូទៅ សំដៅទៅលើអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងសកម្មជននយោបាយ ដែលប្រឆាំងដោយសន្តិវិធី ដោយការប្រឌិតបទចោទប្រកាន់ខាងព្រហ្មទណ្ឌ និងបទចោទមិនត្រឹមត្រូវ ឬចំពោះអំពើដែលមិនត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជាបទល្មើស ដូចជាការប្រឆាំងដោយសន្តិវិធី និងត្រូវធានាឲ្យមានការដោះលែង និងការទម្លាក់បទចោទប្រកាន់ជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ ចំពោះអ្នកទាំងឡាយដែលត្រូវបានចាប់ខ្លួន នាំខ្លួនមកកាត់ទោស ឬដាក់ទោសទណ្ឌ ដោយផ្អែកតែទៅលើការប្រើប្រាស់សិទ្ធិមនុស្សដោយសន្តិវិធី រួមទាំងអ្នកកាសែត អ៊ុនឈិន និងយៀងសុធារិទ្ធ និងសកម្មជនដីធ្លីទេពវណ្ណី។

សូមលោក/លោកស្រី មេត្តាទទួលនូវសេចក្តីរាប់អានដ៏ស្មោះអំពីខ្ញុំ។



ក្លា អាល់ហ្គា (Clare Algar)
នាយកប្រតិបត្តិការលើពិភពលោក
អង្គការលើកលែងទោសអន្តរជាតិ